# ជីវប្រវត្តិ

វេជ្ជបណ្ឌិត

# ថោង នីផាមុនី



ពស. ២៥៦៧

# អារម្ភកថា

ប្រិយមិត្តអ្នកអានជាទីគោរព !

ក្រោយពេលចូលនិវត្តន៍នាងខ្ញុំតែងមើលយូធូប (YouTube) ពិសេសចូលចិត្តមើល និងស្តាប់ធម្មកថិកល្បីៗ ទេសនាអំពីព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដូចជាព្រះអង្គ **ពិន សែម** ព្រះចៅអធិការវត្តរាជបូណ៌ ខេត្តសៀមរាប, ព្រះអង្គ **សាន ភារ៉េត** ព្រះចៅអធិការវត្តឆ្នោត ខេត្តព្រៃវែង, ព្រះអង្គគ្រូ **សាន សុជា** ជាព្រះចៅអធិការវត្តមណីរតនារាម នៅខេត្តពោធិ៍សាត់, ព្រះអង្គ **គូ សុភាព**, ព្រះអង្គ **សំ ប៊ុនធឿន**, លោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស**, លោកគ្រូធម្មាចារ្យ ធម្មានន្ទ និងព្រះអង្គជាធម្មកថិកដ៏ល្បីជាច្រើនទៀត។ល។

ដោយចៃដន្យ ក្នុងខែឧសភា ឆ្នាំ២០២២ នាងខ្ញុំបានឃើញ បានស្តាប់ការសម្តែងព្រះធម៌ដោយពន្យល់និងបកស្រាយសំណួររបស់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ថោង នីដាមុនី** ដែលលោកបានបង្រៀននៅក្នុងទីស្នាក់ការនៃ អង្គការក្តីករុណារៀងរាល់ព្រឹកថ្ងៃសៅរ៍។

បានស្តាប់ហើយ នាងខ្ញុំមានការជក់ចិត្តជិតអារម្មណ៍យ៉ាងក្រៃលែង ដោយហេតុថា លោកគ្រូគឺជាវេជ្ជបណ្ឌិតផ្នែកជំងឺទូទៅផង និងយល់ដឹងច្បាស់លាស់ អំពីព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូទាំង ៨៤,០០០ព្រះធម្មក្ខន្ធព្រះត្រៃបិដក, ព្រមទាំងព្រះវិន័យ, ព្រះសុត្តន្តបិដក, ព្រះអភិធម្ម (វិ.សុអ) យ៉ាងទូលំទូលាយ និងល្អិតល្អន់ទៀតផង។

មុនស្តាប់លោកគ្រូ **ថោង នីដាមុនី** បង្រៀន នាងខ្ញុំមិនទាន់ជឿជាក់ថាការធ្វើសមាធិជួយព្យាបាលជំងឺផ្លូវចិត្តផង ជំងឺផ្លូវកាយផង និងបានបុណ្យច្រើនទៀតផង ព្រោះគិតថាគ្រាន់តែអង្គុយបត់ជើងពែនភ្នែននៅស្ងៀមសោះ ហេតុអ្វីក៏ស័ក្តិសិទ្ធម្ល៉េះ? ប៉ុន្តែទោះជាយ៉ាងណាក៏មិនបានបដិសេធទ្រឹស្តីខាងលើទាំងស្រុងនោះឡើយ។

ក្រោយការស្តាប់លោកគ្រូ **ថោង នីជាមុនី**, ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ, សម្តេចព្រះព្រហ្មរតនមុនី **ពិន សែម** សិរីសុវណ្ណោ, ព្រះអង្គ **ទុំ វចនា** អំពីការធ្វើសមាធិកម្មដ្ឋាន និងវិបស្សនារឿយៗរួបមក នាងខ្ញុំក៏បានបដិបត្តិ តាមឱវាទរបស់ព្រះអង្គម្ចាស់គ្រូនិងលោកគ្រូដូចបានរៀបរាប់ខាងលើរួបមកនាងខ្ញុំមានការជឿជាក់យ៉ាងមុតមាំថាការបដិបត្តិសមាធិ និងវិបស្សនា គឺពិតជាពិសេសមែន។

នាងខ្ញុំព្យាយាម ស្វែងរកទីតាំងលោកគ្រូ **ថោង នីជាមុនី** បង្រៀនធម៌ នៅអង្គការក្តីករុណា ដែលបច្ចុប្បន្ន(២០២៣) មានទីតាំងនៅជិត សាកលវិទ្យាល័យភូមិន្ទកសិកម្ម បំការដូង រាជធានីភ្នំពេញ ព្រមទាំងបានស្តាប់ និងរៀនដោយផ្ទាល់នៅទីនោះ។ ក្រោយមកនាងខ្ញុំ ក៏សម្រេចចិត្តសុំការអនុញ្ញាតិពីលោកគ្រូ **ថោង នីជាមុនី** ដើម្បីសរសេររៀបរៀងជីវប្រវត្តិរបស់លោកគ្រូតាំងពីពេលនោះមក។

ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០២៣

**អ្នករៀបរៀង**

# សេចក្តីផ្តើម

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** (THONG Nidamony) ជាធម្មកថិកដ៏ល្បីល្បាញម្នាក់នៅក្នុងសង្គម ដែលគោរពនិងជឿជាក់លើព្រះពុទ្ធសាសនា និងកំពុងឱ្យតម្លៃយ៉ាងពិសេសកាត់ថ្លៃមិនបានក្នុងការធ្វើសមាធិកម្មដ្ឋាន និងវិបស្សនា។

អាស្រ័យដោយមានបញ្ញាឈ្លាសវៃ ឧស្សាហ៍ព្យាយាម និងមានឧបនិស្ស័យជឿជាក់លើព្រះពុទ្ធសាសនា លោកចូលចិត្តសិក្សាស្រាវជ្រាវព្រមទាំងពិនិត្យសង្កេត អំពីជីវិតរស់នៅរបស់សត្វទូទៅក្នុងពិភពលោក រហូតដល់មានចំណេះដឹងយ៉ាងទូលំទូលាយ ក្នុងភពទាំងបីទៀតផង។

លោកគ្រូ **ថោង នីដាមុនី** គឺជាវេជ្ជបណ្ឌិតឯកទេសជំងឺទូទៅផង ជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាពេទ្យផង ទើបលោកអាចបង្រៀនព្រះធម៌ ព្រមទាំងពន្យល់អំពីបញ្ហាផ្សេងៗ និងដំណោះស្រាយសុខភាព ផ្គួបផ្សំការពន្យល់បែបវិទ្យាសាស្ត្រ (Science Naturelle) អំពីដំណើរការរបស់ខួរក្បាល និងសរីរាង្គសំខាន់ៗ ក្នុងខ្លួនមនុស្ស ដូចជាបេះដូង ថ្លើម, ប្រម៉ាត់, សួត,ក្រពះ,តម្រងនោម ដែលដំណើរការទៅជាប្រព័ន្ធ ហាក់បីដូចជាខ្សែសង្វាក់ផលិតកម្មនៅក្នុងរាងកាយមនុស្ស។ ពិសេសជាងនេះទៅទៀត ការបង្រៀនរបស់ លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** ផ្តោតទៅលើសមាធិ និងវិបស្សនា ធ្វើឱ្យអ្នកស្តាប់មានការយល់ដឹងច្រើន អំពីអត្ថប្រយោជន៍របស់សមាធិ និងវិបស្សនា។

# ការសិក្សា ចំណេះដឹងទូទៅ និងមុខជំនាញបន្ថែម

## ក - ការសិក្សាផ្នែកអាណាចក្រ

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** បានប្រឡងជាប់ និងទទួលបានសញ្ញាបត្រថ្នាក់មធ្យមសិក្សាទុតិយភូមិ (BaccII) នៅឆ្នាំ១៩៨៧ នៅវិទ្យាល័យភូមិភាគខេត្តបាត់ដំបង។

- បន្ទាប់ពីបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លោកបានចូលរៀននៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ នៅឆ្នាំ១៩៩៤ លោកក៏បានរៀនចប់ថ្នាក់វេជ្ជបណ្ឌិតផ្នែកជំងឺទូទៅ។
- លោកបានសិក្សាបន្ថែមនូវមុខវិជ្ជា ដែលពាក់ព័ន្ធនិងការព្យាបាលជំងឺទូទៅ គឺផ្នែកអេកូសាស្ត្រ។
- លោកបានសិក្សាស្រាវជ្រាវអំពីជំងឺកាមរោគ



រូបថតឯកសណ្ឋានពេទ្យ

## ២ - ការសិក្សាផ្នែកពុទ្ធចក្រ

អាស្រ័យដោយមានឧបនិស្ស័យ មានសទ្ធាយ៉ាងមុតមាំលើសាសនាព្រះពុទ្ធ លោកបានសិក្សាយ៉ាងយកចិត្តទុកដាក់ ដោយស្ម័យសិក្សាទាំងយប់ទាំងថ្ងៃ និងធ្វើការស្រាវជ្រាវអំពីសៀវភៅផ្សេងៗជាច្រើន និងគ្រប់ទីកន្លែងតាមបណ្ណាគារ បណ្ណាល័យ ឬទីវត្តអារាមផ្សេងៗជាដើម។

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីជាមុនី** សិក្សាទាំងអស់ ទាំងព្រះត្រៃបិដក ៨៤,០០០ ព្រះធម្មក្ខន្ធ, ទាំងព្រះវិន័យ, ព្រះសុត្តន្តបិដក, និងព្រះអភិធម្ម(វិ.សុអ) ដោយមិនមានគ្រូបាអាចារ្យណាបង្រៀនលោកនោះឡើយ មានតែការព្យាយាម តាមបំណងបំណូលចិត្ត និងឧបនិស្ស័យពីកំណើតពីអតីតជាតិ ជាអនេកជាតិមក ហើយធ្វើឱ្យលោកមិនធឿយណាយ មិនធំអក់ធុញទ្រាន់ក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៀត ផ្នែកមនុស្សសាស្ត្រយ៉ាងច្បាស់ និងទូលំទូលាយ។

មិនតែប៉ុណ្ណោះលោកសាស្ត្រាចារ្យព្យាយាមស្វែងសិក្សាដោយខ្លួនឯង តាមគម្ពីនានាអំពីការធ្វើសមាធិ និងវិបស្សនាទៀតផង។









រូបថត

# ចំណង់ចំណូលចិត្ត

- លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** ចូលចិត្តអានសៀវភៅ ដូចជាសៀវភៅ ដែលពាក់ព័ន្ធទៅនិងការព្យាបាលជំងឺ និងការថែទាំសុខភាពជាដើម។
- ចូលចិត្តអានសៀវភៅ ដែលពាក់ព័ន្ធជាមួយនឹងព្រះពុទ្ធសាសនា សៀវភៅព្រះត្រៃបិដកទាំង ១១០ក្បាល គឺលោកអានទាល់តែចេះចាំ និងយល់ច្បាស់ ព្រោះលោកមានប្រាជ្ញាឈ្លាសវៃ ឆាប់ចាំ ឆាប់ចេះ។
- អានសៀវភៅទាក់ទងនឹងព្រះពុទ្ធសាសនា ផ្នែកព្រះវិន័យ សុត្តន្តបិដក និងព្រះ អភិធម្ម។
- ចូលចិត្តសិក្សាស្រាវជ្រាវពីសៀវភៅបរទេស អ្នកប្រាជ្ញល្បីៗ លើពិភពលោក រៀបរាប់អំពីចិត្តសាស្ត្រ មនុស្សសាស្ត្រ សង្គមសាស្ត្រ និងច្បាប់ចក្រវាឡជាដើម។
- ចូលចិត្តពន្យល់ បង្ហាត់បង្ហាញ រាល់ចំណេះដឹងដែលលោកបានយល់ និងចេះចាំដល់មនុស្សគ្រប់វ័យ គ្រប់វណ្ណៈទាំងអស់។
- ចូលចិត្តនិយាយលេងកំប្លុកកំប្លែង ដើម្បីឱ្យបរិយាកាសជុំវិញខ្លួនលោក បានរីករាយសប្បាយស្រស់បំព្រង។
- ចូលចិត្តធ្វើសមាធិ និងវិបស្សនា ដោយមិនរើសទីតាំង ឬពេលវេលានោះឡើយ។
- ចូលចិត្តជួយសង្គ្រោះ មិនថាមនុស្ស ឬសត្វ មិនថាពណ៌សម្បុរ ពូជសាសន៍អ្វីនោះឡើយ។

# ការងារនិងសង្គម

## ក - ការងារជាសារវន្ត

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង និដាមុនី** (THONG Nidamony) បានចូលបម្រើការងារនៅក្រសួងសុខាភិបាល នៅឆ្នាំ១៩៩៤ បន្ទាប់ពីលោកបានប្រឡងជាប់ និងទទួលបានសញ្ញាបត្រជាវេជ្ជបណ្ឌិតឯកទេសជំងឺទូទៅ។

## ខ - មុខងារបន្ទាប់បន្សំ

ក្រៅពីការងារជាមន្ត្រីរាជការ លោកសាស្ត្រាចារ្យធ្លៀតបង្រៀននិស្សិត នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ខេមរភូមិន្ទ តាំងពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន (២០២៣)។






រូបថតកំពុងបង្រៀន

### គ - មុខរបរចិញ្ចឹមជីវិត:

ក្រៅពីការងារបម្រើជាតិ ជាមន្ត្រីរាជការ ជាសាស្ត្រាចារ្យវេជ្ជបណ្ឌិត លោកបាន បម្រើការងារនៅគ្លីនិកឯកជនមួយ ដែលមានឈ្មោះថា(មន្ទីរសម្រាកព្យាបាល **ប្ញទ្ធីតា**) មាន ទីតាំងនៅសង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ទល់មុខរោងចក្រ **ស៊ីកូ** តាមបណ្តោយផ្លូវជាតិលេខ៣។

### ឃ- ទេពកោសល្យ

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីជាមុនី** មានទេពកោសល្យ ខាងបង្ហាត់ បង្ហាញ ពន្យល់ បង្រៀន អប់រំផ្លូវចិត្ត តាមទ្រឹស្តីព្រះពុទ្ធសាសនា ផ្គួបផ្សំនិងទ្រឹស្តីវេជ្ជសាស្ត្រ វិទ្យាសាស្ត្រ មនុស្សសាស្ត្រ និងសង្គមសាស្ត្រដោយមានលើកឧទាហរណ៍ជាក់ស្តែងផ្សេងៗ គ្នាយ៉ាងពិរោះរណ្តំ ដែលលោកសន្សំមកពីការអាន ការស្តាប់និងបទពិសោធន៍ក្នុងជីវិត របស់លោកជាច្រើនឆ្នាំ យកមកបញ្ជាក់ បង្ហាញអ្នកស្តាប់ឱ្យបាន យល់ពីព្រឹត្តិការណ៍ ឬ បាតុភូតនានាពាក់ព័ន្ធនិង ជីវិតរស់នៅប្រចាំថ្ងៃ។

លើសពីនេះទៅទៀត លោកសាស្ត្រាចារ្យ មានទេពកោសល្យពន្យល់ដោយលើក ហេតុនឹងផលប្រកបដោយទឹកចិត្តមេត្តានិងខន្តីធម៌។ ដោយកាយវិការដ៏មានសប្បុរសនេះ ហើយ ដែលធ្វើឱ្យមហាជនអ្នកស្តាប់ចូលចិត្តគ្រប់ៗគ្នា ញ៉ាំងឱ្យមានបរិយាកាសរីករាយក្នុង ការធ្វើធម្មទានដែលជាទានដ៏វិសេសបំផុត។

# ការងារជួយសង្គមជាតិកម្ពុជា

តាំងពីក្មេងរហូតមកលោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** មានឧបនិស្ស័យ បេះម្ចាស់ការ ដឹកនាំខ្លួនឱ្យមានវិន័យ មានសណ្តាប់ធ្នាប់រៀបរយ។ មានចរិកឧស្សាហ៍ ព្យាយាម តស៊ូរៀនសូត្រ និងធ្វើរាល់កិច្ចការប្រចាំថ្ងៃប្រចាំជីវិត នូវរាល់ការងារដែលមិនផ្ទុយនិងច្បាប់ ដែលរាជរដ្ឋាភិបាលបានកំណត់។

បន្ទាប់ពីបានបញ្ចប់ការសិក្សា និងទទួលបានសញ្ញាបត្រផ្នែកវេជ្ជបណ្ឌិត ឯកទេសជំងឺទូទៅ លោកបានស្ម័យសិក្សាបំណេះដឹងផ្នែកព្រះពុទ្ធសាសនាបេះចាំស្ទាត់ជំនាញ នូវព្រះធម៌ទាំង ៨៤,០០០ព្រះធម្មក្ខ័ន្ធ ព្រះសុត្តន្តបិដក ព្រះវិន័យ និងព្រះអភិធម្ម លោកមានសណ្តានចិត្តចង់ចែករំលែកនូវបំណេះដឹងរបស់លោកដល់ប្រជាជន ជាពិសេសក្មេងជំនាន់ក្រោយដែលជាសរសរទ្រូងរបស់ប្រទេសជាតិ។

លោកបានស្ម័គ្រចិត្តបង្រៀនក្នុងនាមជាសាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យផ្សេងៗ ចាប់តាំងពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។

ឆ្នាំ២០០៤ លោកគ្រូ វេជ្ជបណ្ឌិត **ថោង នីដាមុនី** កើតបីតិ ប្រមូលកូនសិស្សនៅសាលា ដែលលោកបានបង្រៀនផ្នែកវេជ្ជសាស្ត្រ មករៀនរៀងរាល់ថ្ងៃសៅរ៍ ក្រោមម្លប់ដើមស្វាយ១ដើម អង្គុយលើគ្រែ ដែលលោកយាយ **ឆន** បានអនុញ្ញាត និងមានសទ្ធាក្នុងការផ្តល់កន្លែងឱ្យលោកបង្រៀន និងបកស្រាយព្រះធម៌នៅច្បារអំពៅ រាជធានីភ្នំពេញ។

ក្រោយមក ដោយសារតែទីកន្លែងចាស់ (ក្រោមម្លប់ស្វាយ) ត្រូវបានលក់ចេញ លោកគ្រូ វេជ្ជបណ្ឌិត **ថោង នីដាមុនី** បានផ្លាស់ប្តូរទៅបង្រៀននៅក្នុងវត្តនិរោធរង្សី ក្នុងខ័ណ្ឌច្បារអំពៅដដែលបានមួយរយៈក៏បានផ្លាស់ប្តូរទីតាំងថ្មីមួយទៀត។ ប៉ុន្តែមុនផ្លាស់ប្តូរទីតាំងបង្រៀនពីវត្តនិរោធរង្សី លោកបានយល់សុបិនឃើញព្រះព្រហ្មមួយព្រះអង្គយ៉ាងធំស្រស់ស្អាត ហើយទ្រង់គ្រឿងដណ្តប់ដោយមាសភ្លឺ ចិញ្ចាចចិញ្ចែង ហើយយកព្រះហស្តព្រះអង្គមកទ្រលោកគ្រូហោះឡើងទៅលើអាកាស(មេឃ)។

ក្នុងសុបិន្ត លោកគ្រូ វេជ្ជបណ្ឌិត **ថោង នីជាមុនី** មើលពីលើមេឃមកឃើញមនុស្សដើរតូចៗ ផ្លូវឆ្ងាយ ដូចផ្លូវទៅនិព្វាន ក្នុងនោះក៏ឃើញលោកយាយ **ឆន** ដែលជាអ្នកផ្តល់ទីតាំងបង្រៀនដំបូងនៅក្រោមម្លប់ស្វាយមួយដើម ដើរជាមួយគ្នាផងដែរ។

## លោកអ្នកអានជាទីមេត្រី!

ការផ្សព្វផ្សាយព្រះធម៌របស់លោកគ្រូ វេជ្ជបណ្ឌិត **ថោង នីជាមុនី** មានដំណើរតស៊ូ និងកំសត់ណាស់រហូតជ្រួតជ្រាបដល់ឋានព្រះព្រហ្ម។ ក្រោយពីសុបិន្តលោកគ្រូក៏បានជួបឧបាសក **ចាន់ គុកស្រ៊ុន** ហើយរៀបរាប់ពីកន្លែងបង្រៀន ដែលផ្លាស់ប្តូរពីមួយកន្លែងទៅមួយកន្លែង។

នៅកំឡុងឆ្នាំ២០១៦ លោកបានផ្លាស់ប្តូរទីតាំង ពីទីតាំងចាស់ទៅបង្រៀននៅទីតាំងថ្មីមួយទៀតដែលបច្ចុប្បន្នជាប់នឹងមហាវិថី៦០ម៉ែត្រនៅចម្ការរបស់ឧបាសក**ចាន់ គុកស្រ៊ុន** ក្រោមម្លប់ឬស្សីដែលរៀបចំជាកញ្ចុះនិងគ្រែសម្រាប់ការរៀន។ ក្រោយមកលោកឧបាសក **ចាន់ គុកស្រ៊ុន** និងភរិយា មានសទ្ធាជ្រះថ្លាក្រៃលែងក៏បានកសាងសាលាធម្មសភាមួយសម្រាប់បង្រៀន ដែលមានឈ្មោះថាសាលាធម្មសភាចម្ការត្របែក ហើយលោកបានរៀបចំទីសេនាសេនៈ តម្កល់រូបបដិមាព្រះសម្មាសម្ពុទ្ធយ៉ាងស្រស់ស្អាតផងដែរ។

ក្នុងការផ្សព្វផ្សាយព្រះធម៌ លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីជាមុនី** បានយកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រផ្គួបផ្សំនិងទ្រឹស្តីព្រះពុទ្ធសាសនា ដើម្បីសិស្សងាយស្រួលយល់កាន់តែច្បាស់ និងទូលំទូលាយ។

ក្នុងការផ្សព្វផ្សាយព្រះធម៌លោកគ្រូវេជ្ជបណ្ឌិត **ថោង នីជាមុនី** បានយកព្រះត្រៃបិដកមកអាន និងបកស្រាយពន្យល់អំពីដំណោះស្រាយជីវិតឱ្យរួចផុតបាកទុក្ខ ដោះស្រាយព្យាបាលជំងឺផ្លូវចិត្ត បញ្ហាគ្រួសារ លោកបានពន្យល់រហូតដល់លែងមានជម្លោះទាស់ទែងក្នុងគ្រួសារបានមួយចំនួនផងដែរ។

ដោយខិតខំព្យាយាមតស៊ូ បែករំលែកបំណោះដឹង ផ្ទេកព្រះពុទ្ធសាសនាឱ្យរុងរឿង

ផ្សព្វផ្សាយទូលំទូលាយ នៅក្នុងសាកលលោកយ៉ាងនេះក្តី ក៏មានបុគ្គលបិត្តមារមួយចំនួនបានតិះដៀលលោក ដោយពាក្យសម្តីអាក្រក់ៗជាច្រើន និងបានមើលងាយបន្ទាបព្រះធម៌ថាលោក យកទិន្នន័យសម្រាមមកដាក់ក្នុងសង្គម យកព្រះពុទ្ធសាសនាមកបន្ទាបជាមួយវិទ្យាសាស្ត្រជាដើម។ ទោះបីទទួលពាក្យនិន្ទាពីបុគ្គលមួយចំនួនយ៉ាងណាក៏ដោយ លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ខៅាច នីជាមុនី** មិនតបតដោយកំហឹង គឺលោកមានតែស្រណោះសត្វលោក ដែលមិនទាន់ស្វែងយល់ពីអត្ថន័យព្រះធម៌ ពីភាពអស្ចារ្យរបស់ព្រះធម៌ ហើយព្យាយាមពន្យល់បន្តិចម្តងៗ។

នៅកំឡុងឆ្នាំ២០១៨ ចាប់ផ្តើមមានការថតផ្សាយ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយយូធូប (YouTube) ដែលមានឈ្មោះថា Buddhist-Knowledge ធ្វើឱ្យអ្នកស្តាប់កាន់តែកើនឡើងៗជាលំដាប់ទាំងក្នុងប្រទេស និងក្រៅប្រទេសរហូតដល់មានពុទ្ធបរិស័ទខ្លះ បានពោលថាក្រោយពីបានស្តាប់ការបកស្រាយក៏ ដូចជាការពន្យល់ផ្សេងៗ របស់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ខៅាច នីជាមុនី** ទើបដឹងកាន់តែច្បាស់ថា ព្រះធម៌ពិតជាអស្ចារ្យខ្លាំងណាស់ ដែលមិនអាចកាត់ថ្លៃ ឬយកអ្វីប្រៀបផ្ទឹមពុំបាន។

គិតមកត្រឹមខែមិថុនា ឆ្នាំ២០២៣នេះ ការសម្តែងនិងការឡាយវីដេអូ តាមរយៈយូធូប (YouTube) ដែលមានឈ្មោះថា Buddhist-Knowledge មានចំនួន ៦៩២វីដេអូ ហើយមានអ្នកចូលទស្សនា និងសិក្សាតាមរយៈឃ្លីបវីដេអូពន្យល់ផ្សេងៗ មានចំនួនជាច្រើនដងៗ។ ពុទ្ធបរិស័ទក្នុងប្រទេស និងក្រៅប្រទេសមានការកើនឡើង ក្នុងការចូលទស្សនាពីមួយថ្ងៃទៅមួយថ្ងៃ ព្រមទាំងមានការចូលរួមជាមតិសួរ រាល់ចម្ងល់ផ្សេងៗ ក៏ដូចជាផ្តល់ជាមតិយោបល់ផ្សេងៗជាច្រើនទៀត ឬក៏រាល់មន្ទិលផ្សេងៗក្នុងកិច្ចបដិបត្តិព្រះធម៌រៀងៗខ្លួន។ ពុទ្ធបរិស័ទខ្លះបានពោលនៅក្នុងប្រព័ន្ធយូធូបថា ក្រោយពេលបានស្តាប់ការពន្យល់ផ្សេងៗរបស់សាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ខៅាច នីជាមុនី** ជាធម្មកថិកសម្តែងព្រះធម៌ បូកផ្សំជាមួយវិទ្យាសាស្ត្រ វេជ្ជសាស្ត្រ បកស្រាយពន្យល់អំពីកិច្ចបដិបត្តិសមាធិ និងអត្ថប្រយោជន៍ផ្សេងៗជាច្រើន ដែលធ្វើឲ្យជីវិតបានយល់ច្បាស់អំពីសច្ចៈធម៌ ដោយលើក

ឧទាហរណ៍មកបញ្ជាក់ច្បាស់ៗទៀតផង។ ម្យ៉ាងវិញទៀត លោកតែងតែដឹកនាំសិស្សរបស់លោកទៅថ្វាយបង្គំនៅពុទ្ធស្ថានានា និងអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា។

នៅឆ្នាំ២០១៩ ដោយសារបញ្ហាជំងឺកូវីដរីករាលដាលពេញសាកលលោក ទីតាំងបង្រៀននៅសាលាធម្មសភាបុប្ផារត្នបែកក៏បានផ្អាកជាបណ្ដោះអាសន្ន ដោយគោរពតាមរាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យមានការជួបជុំគ្នា ដើម្បីបញ្ចៀសការឆ្លងរីករាលដាលនៃជំងឺដ៏កាចសាហាវមួយនេះ(ជំងឺកូវីដ)។ ក្រោយសម្រាកមួយរយៈពេល ក៏មានពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លាបានផ្ដល់ទីកន្លែងក្នុងការបង្រៀននិងផ្សព្វផ្សាយព្រះធម៌គឺ**អង្គការភ្លើករុណា** ដែលលោក **ទឹម មិនា** ជាប្រធានអង្គការនិងជាអ្នកសិក្សាស្វែងយល់ព្រះធម៌យ៉ាងច្បាស់។ ចាប់ពីពេលនោះមក ទីកន្លែងបង្រៀនធម៌ក៏បានផ្លាស់ប្ដូរទៅបង្រៀនព្រះធម៌ រៀងរាល់ថ្ងៃសៅរ៍ ពេលព្រឹក នៅទីស្នាក់ការ**អង្គការភ្លើករុណា** ជិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម បំការដូង រាជធានីភ្នំពេញ (២០២៣) មានសិស្សក្មេងចាស់ ប្រុសស្រី គ្រប់វ័យ ចូលមកស្ដាប់លោកពន្យល់ព្រះធម៌ និងបកស្រាយបញ្ហាផ្សេងៗជាច្រើន។ លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង និជាមុនី** បានបង្កើតក្រុមព្រះធម៌ តាមរយៈប្រព័ន្ធតេលេក្រាម (Telegram) ដែលមានសមាជិកនិងសិស្សប្រហែល១,១៣៩នាក់ ដើម្បីបកស្រាយនូវសំណួរចម្លើយអំពីព្រះធម៌ ក៏ដូចជាបញ្ហាផ្សេងៗឬចម្ងល់ក្រោយពេលស្ដាប់ឬបដិបត្តិសមាធិកម្មដ្ឋានលើសពីនេះទៀត លោកបានបកស្រាយរាល់បញ្ហាផ្សេងៗ ដូចជាបញ្ហាផ្លូវចិត្ត បញ្ហាគ្រួសារ និងបញ្ហាសុខភាពទៀតផង។

ការគិតពិចារណា អំពីកិច្ចបដិបត្តិព្រះធម៌ ទាំងសមាធិកម្មដ្ឋាន និងវិបស្សនា របស់លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង និជាមុនី** ឃើញថាលោកបានធ្វើដំណើរ តាមមាគ៌ារបស់ព្រះសម្មាសម្ពុទ្ធ ដូចស្រមោលអន្ទោលតាមប្រាណ ព្រោះថាក្រោយពីការសិក្សាស្វែងយល់អំពីទ្រឹស្ដីព្រះពុទ្ធសាសនាបានច្បាស់ រួមទាំងការពិនិត្យសង្កេត អំពីដំណើរជីវិតរបស់សត្វលោកក្នុងសង្សារវដ្ដនេះបានល្អិតល្អន់ហាក់បីដូចជាព្រះពុទ្ធក្រោយការត្រាស់ដឹងហើយព្រះអង្គចេញប្រោសសត្វ ដូចចែងក្នុងពុទ្ធនិយាម៣០។ ត្រង់និយាម ទី១៤ "ដប់បួនដួនព្រហ្ម

ជុំអារាធនា សូមព្រះភគវា យាងត្រាស់សម្ដែង ព្រះធម៌ប្រពៃ វិស័យសួរសែង ទ្រង់ព្រម សម្ដែងដោយព្រហ្មវិហារ” និងនៅត្រង់និយាម២៤ “ម្ដេចបួនអង្គេន ហឫទ័យ ករុណា ជាតក ទេសនា សាស្ដាលកលៃ ដើមរឿងជាហេតុ បង្កើតអត្ថន័យ ជាតកប្រពៃលៃ តាម ហេតុការណ៍”។

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** ក៏បដិបត្តិតាមព្រះពុទ្ធបរមគ្រូ ចាប់តាំងពីឆ្នាំ២០០៤ រហូតមកដល់បច្ចុប្បន្ននេះ(២០២៣) លោកបានសម្ដែងព្រះធម៌ អាន សៀវភៅព្រះត្រៃបិដក ក៏ដូចជាសៀវភៅព្រះធម៌ផ្សេងៗជាច្រើនទៀត ព្រមទាំងដោះ ស្រាយរាល់ចម្ងល់ផ្សេងៗជាច្រើន ដែលសិស្សក៏ដូចជាពុទ្ធបរិស័ទបានសួរ ទាក់ទងនឹង ព្រះធម៌ ឬកិច្ចបដិបត្តិ។ មិនតែប៉ុណ្ណោះលោកវេជ្ជបណ្ឌិត **ថោង នីដាមុនី** ធ្វើការបក ស្រាយរាល់បញ្ហាសុខភាព និងដំណើរការនៃសរីរាង្គក្នុងខ្លួន ពិសេសជាងនេះទៅទៀត លោកគ្រូបានផ្ដោតយ៉ាងខ្លាំងទៅលើការធ្វើសមាធិកម្មដ្ឋាន និងវិបស្សនាផងដែរ។



រូបថតធម្មសភាចំការត្របែក



នៅថ្មីៗនេះឧបាសិកា **ខុត្តរៈ ពិសី** ដែលមានជីតាជាព្រះសង្ឃ និងជាគ្រូសមាធិបានពន្យល់សប្តិប្រាប់ ឱ្យតាមលោកគ្រូសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីជាមុនី** មកគេហដ្ឋានឱ្យទាល់តែបាន។ ឧបាសិកា **ខុត្តរៈ ពិសី** ក៏តាមស្វែងរករហូតដល់មួយរយៈក្រោយមកទើបជួបលោកគ្រូ **ថោង នីជាមុនី** និងបានអញ្ជើញលោកគ្រូ និងសិស្សរបស់លោកទៅកាន់គេហដ្ឋានផ្ទាល់នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ ទៅតាមបណ្តាំរបស់ជីតាដែលបានពន្យល់សប្តិ។



## ការគាំទ្ររបស់សង្គម

មិត្តអ្នកអានជាទីមេត្រី!

អាស្រ័យដោយមានការផ្សព្វផ្សាយតាមយូធូបឆានែល YouTube ដែលមានឈ្មោះ ប៉ា Buddhist- Knowledge បាន៦៩២ឃ្លីបវីដេអូ អ្នកចូលមើលជាច្រើនដង និងប្រព័ន្ធ Facebook មានអ្នកទស្សនាទាំងក្នុង និងក្រៅប្រទេស។ ក្រសួងធម្មការ និងសាសនានៃព្រះរាជាណាចក្រកម្ពុជាបានបេញសង្ឃប្រកាស ស្ដីអំពីការតែងតាំង លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីជាមុនី** ជាទីប្រឹក្សាសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** កិត្តិឧទ្ទេសបណ្ឌិត សម្ដេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ ចុះហត្ថលេខាដោយសម្ដេចព្រះមហាសង្ឃរាជ **ទេព វង្ស**។




រូបថតសង្ឃប្រកាស

លើសពីនេះទៀត នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ មានសេចក្ដីត្រាស់បង្គាប់ មួយទៀតចុះហត្ថលេខាដោយព្រះមហាសង្ឃរាជាធិបតី **ប៊ូ គ្រី** គតិឱទ្ទេសបណ្ឌិត សម្ដេចមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជាតែងតាំងលោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** ជាទីប្រឹក្សា។



**រូបថតសង្ឃប្រកាស**



រូបថតសង្ឃប្រកាស

ដោយអានុភាពនៃបុញ្ញាកម្ម និងការលះបង់សម្រាប់ព្រះពុទ្ធសាសនា សូមឲ្យលោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ថោង នីដាមុនី** និងក្រុមញាតិ ព្រមទាំងសត្វលោកទាំងអស់ បាននូវសេចក្ដីសុខសន្តិភាព ជួយទ្រទ្រង់ជាតិទៅមុខ ទោះនៅទីណាឋានណា មានបញ្ញារំដោះទុក្ខភ័យខ្លួនឯង និងជួយអ្នកដទៃឲ្យបាននិព្វានឆាប់ៗកុំបីខានឡើយ។

សូមអរព្រះគុណ និង អរគុណ

ជីវិតសល់តែស្លាកស្នាមអនុស្សាវរីយ៍
ដែលវេចស្លាយសុទ្ធតែជាគំនរអារម្មណ៍
បង្កជាវិបាកសុខទុក្ខតជាតិ តភពជាប់មិន
ដាច់ទៅតាមអំពើដែលខ្លួនបានធ្វើតែប៉ុណ្ណោះ
ការបញ្ចប់ជាតិកំណើតទើបចប់ទុក្ខ។